# កម្មវិធីជំនួយជនរងគ្រោះ/សាក្សី

### តើកម្មវិធីជួយជនរងគ្រោះ និងសាក្សី ជាអ្វី?

បើសិនអ្នកជាជនរងគ្រោះ ឬជាសាក្សីនៃឧក្រិដ្ឋកម្មហឹង្សា អ្នកប្រហែលជាត្រូវទៅតុលាការ។

ការពិសោធន៍នេះ អាចជាលំបាក និងភាន់ច្រឡំ។ អ្នកប្រហែលជាមានសំណួរច្រើន អំពីប្រព័ន្ធយុត្តិធម៌នៃបទឧក្រិដ្ឋ ហើយអ្វីខ្លះដែលត្រូវបានរំពឹងពីអ្នក។

**កម្មវិធីជួយជនរងគ្រោះ និងសាក្សី គឺត្រៀមបំរុងជួយអ្នក។** យើងនឹងនិយាយជាមួយអ្នក និងផ្តល់ជំនួយឲ្យអ្នក យោងទៅលើស្ថានការណ៍ និងសេចក្តីត្រូវការជាក់លាក់ របស់អ្នក។

សេវារបស់យើងចាប់ផ្តើម ដូចជា ថ្ងៃឈ្នួលនគរបាលបានផាក និងបន្តរហូតដល់ទីបញ្ចប់នៃរឿងក្តីតុលាការ។

### តើអ្នកណាខ្លះ អាចទទួលជំនួយ?

សេវាទាំងនេះត្រូវបានផ្តល់ទៅឲ្យជាចំបង សំរាប់ជនរងគ្រោះ និងសាក្សីដែលទន់ខ្សោយ អំពីសំណាក់ឧក្រិដ្ឋកម្មហឹង្សា ដូចជា អំពើហឹង្សាក្នុងគ្រួសារ ការធ្វើទុក្ខទោសក្មេង ការធ្វើបាបផ្លូវភេទ ការធ្វើទុក្ខទោសមនុស្សចាស់ៗ មនុស្សឃាត និងឧក្រិដ្ឋកម្មសំអប់។

យើងក៏ផ្តល់ជំនួយទៅឲ្យ :

- ជនរងគ្រោះដែលមានសេចក្តីត្រូវការពិសេស
- គ្រួសារជនរងគ្រោះនៃនរឃាតកម្ម
- គ្រួសារជនរងគ្រោះនៃការស្លាប់ដោយសារគ្រោះថ្នាក់ ដែលបណ្តាលឲ្យជាប់ចោទបទឧក្រិដ្ឋ។

វាផ្តល់សេវានានា និងព័ត៌មានសមរម្យ សំរាប់ក្មេងៗ អាស្រ័យទៅលើអាយុរបស់គេ។

### តើខ្ញុំទទួលអាចជំនួយ ដោយរបៀបណា?

បន្ទាប់ពីធ្វើការចោទរួច នគរបាល ឬរាជអាជ្ញា (មេធាវីដើមក្តី) នាំជនរងគ្រោះ និងសាក្សី ទៅកម្មវិធីសំរាប់ជំនួយ។ បើសិនអ្នកជាជនរងគ្រោះនៃឧក្រិដ្ឋកម្មហឹង្សា អ្នកក៏អាចទទួលកម្មវិធីដោយផ្ទាល់បានដែរ ឬស្នើអ្នកណាម្នាក់នៅក្នុងសហគមន៍របស់អ្នកឲ្យទូរស័ព្ទជំនួសអ្នកបាន។ បុគ្គលិកនឹងខ្នះខ្នែងឆាប់ទាក់ទងមកអ្នក ដើម្បីផ្តល់ការគាំទ្រ និងឆ្លើយសំណួរអំពីកង្វល់សុវត្ថិភាព ដែលអ្នកអាចនឹងមាន។

## តើវាថ្លៃប៉ុន្មាន?

សេវាទាំងនេះ គឺផ្តល់ជូនដោយឥតគិតថ្លៃ នៅសព្វពាសពេញខែត្រអនតារីយ៉ូ។

## តើមានជំនួយប្រភេទអ្វីខ្លះ?

កម្មវិធីជំនួយជនរងគ្រោះ និងសាក្សី អាច :

- ឆ្លើយសំណួររបស់អ្នក អំពីប្រព័ន្ធយុត្តិធម៌នៃបទឧក្រិដ្ឋ ទំរង់ការនៅក្នុងតុលាកា និងតួនាទីរបស់គេនៅក្នុងតុលាការ
- ជួយពន្យល់អ្នក អំពីអ្វីៗដែលរំពឹង នៅពេលអ្នកទៅតុលាការ និងប្រុងប្រៀបខ្លួនឲ្យស្រេចបាច់ ដើម្បីបង្ហាញខ្លួននៅតុលាការ។
- ផ្ញើសំណៅនៃឯកសារតុលាការ ដូចជាលក្ខខ័ណ្ឌនៃការលោះខ្លួន និងបទបញ្ជាការល្បងខ្លួន
- ស្ថាបនាការទាក់ទងជំនួសអ្នក ពីសំណាក់រាជអាជ្ញា ឬមន្ត្រីនគរបាល ដែលទទួលបន្ទុកនៃករណីរបស់អ្នក
- ផ្តល់ការគាំទ្រខាងផ្លូវចិត្តជាហូរហែ សព្វទាំងដំណើរការជំនុំជំរះ
- ណែនាំអ្នកឲ្យទៅភ្នាក់ផ្សេងទៀតក្នុងសហគមន៍ សំរាប់សេវាដែលអ្នកអាចនឹងត្រូវការ ដូចជា ការប្រឹក្សា និងគំរោងសុវត្ថិភាព
- ចាត់ចែងអ្នកបកប្រែភាសារបស់អ្នក ក្នុងករណីនៃអំពើហឹង្សាក្នុងគ្រួសារ និង/ឬ ការកែសំរួល ដើម្បីពិចារណាអំពីសេចក្តីត្រូវការពិសេសរបស់គេ
- ជួយពន្យល់អ្នក និងបំពេញ សេចក្តីប្រកាសឥទ្ធិពលនៃជនរងគ្រោះ (សេចក្តីថ្លែងឥទ្ធិពលនៃជនរងគ្រោះ)។

កម្មវិធីមិនអាច :

- ទទួលសក្ខីភាព គឺដំណើរជាសាក្សី ឬភស្តុតាង ឬនិយាយអំពីរឿងរ៉ាវ
- ដកហូតបទចោទ
- ផ្តល់ ឬចាត់ចែងការមើលថៃក្មេង
- ផ្តល់យានជំនិះ ដើម្បីទៅ ឬ មកពីតុលាការ

## តើខ្ញុំអាចទាក់ទង ជាមួយនឹងកម្មវិធីដោយរបៀបណា?

កម្មវិធីជំនួយជនរងគ្រោះ និងសាក្សី បានផ្តល់ជូនដោយ ក្រសួងនៃអគ្គមេធាវី *(Ministry of the Attorney General)* នៅក្នុងមណ្ឌលតុលាការទាំងអស់ 54 កន្លែង

ដើម្បីរកការិយាល័យដែលឋិតនៅជិតអ្នក សូមទូរស័ព្ទទៅ

**ខ្សែជំនួយ សំរាប់ជនរងគ្រោះ**

លេខឥតចេញថ្លៃ 1-888-579-2888 ឬ

416-314-2447 ក្នុងតំបន់ជុំជិត តូរ៉ុនតូ

ឬ ទស្សនា

**www.ontario.ca/victimservices**

(Cambodian)